**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 07-Aug-2019, 10:46
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ [ឯកសារ F47/1 កថាខណ្ឌ ២៥-២៦(ii)]**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Dounia HATTABI

លោក Stéphane NICOLAÏ

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS (ព្រះរាជអាជ្ញាបម្រុង)

លោក William SMITH (ព្រះរាជអាជ្ញារង)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ មេធាវីការពារក្តីលោក ខៀវ សំផន (“មេធាវីការពារក្តី”) បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល (“តុលាការកំពូល”) អនុញ្ញាតឱ្យខ្លួនដាក់សារណាបណ្តឹងសាទុក្ខកម្រាស់ ៩៥០ ទំព័រ ជាភាសាបារាំង ក្នុងរយៈពេល ១០,៥ ខែ គិតចាប់ពីពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងដាក់សំណៅបកប្រែជាភាសាខ្មែរ តាមក្រោយ ឱ្យបានឆាប់បំផុត[1]។

២. នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ ភាគីបានទទួលការជូនដំណឹងអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើនេះ[2]។ សហព្រះរាជអាជ្ញាបានជំទាស់ ដោយបានអះអាងថា រយៈពេល ៥ ខែ និងកម្រាស់ ៣០០ ទំព័រ សម្រាប់ឱ្យក្រុមមេធាវីការពារក្តីនីមួយៗដាក់សារណាបណ្តឹងសាទុក្ខ តែមួយភាសាជាមុនសិន គឺគ្រប់គ្រាន់ហើយ[3]។ សហព្រះរាជអាជ្ញាបានស្នើសុំថា ការបន្ថែមណាមួយជូនមេធាវីការពារក្តីត្រូវធ្វើឡើង “ក្នុងលក្ខណៈសមាមាត្រគ្នា” ទៅនឹងសារណាតបរបស់ខ្លួន[4]។

៣. នៅថ្ងៃដដែលនោះ មេធាវីការពារក្តីលោក នួន ជា បានដាក់សំណើ “លើកទីមួយ” សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន។ មេធាវីការការពារក្តីលោក នួន ជា បានស្នើសុំដាក់សារណាកម្រាស់ ១០០០ ទំព័រ ក្នុងរយៈពេល ១០,៥ ខែ តែមួយភាសាជាមុនសិន គិតចាប់ពីពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[5]។

---

[1] សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ឯកសារ **F45**។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៨ ឯកសារ **F45/2** (“ចម្លើយតប **F45/2**”) ជូនដំណឹងជាភាសាបារាំង នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨។

[3] ចម្លើយតប **F45/2** កថាខណ្ឌ ១៧ និង កថាខណ្ឌ ២២។

[4] ចម្លើយតប **F45/2** កថាខណ្ឌ ១៨ និង កថាខណ្ឌ ២២។

[5] សំណើបន្ទាន់លើកទីមួយរបស់លោក នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ដាក់សារណាលើបណ្តឹងសាទុក្ខជំទាស់នឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ ឯកសារ **F47**។

៤. នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្តីបានឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា[6]។ មេធាវីការពារក្តីមិនបានជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងសារណាតបនោះទេ ពីព្រោះសំណើនេះហាក់ដូចជាសមហេតុផល។

៥. នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ភាគីបានទទួលការជូនដំណឹងអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ របស់មេធាវីការពារក្តីលោក នួន ជា ដែលសហព្រះរាជអាជ្ញាបានជំទាស់[7]។ លើកនេះ សហព្រះរាជអាជ្ញាបានស្នើសុំ "៧០% នៃចំនួនទំព័រសរុបរួម និង ៥០% នៃពេលវេលារួម ដែលផ្តល់ជូនមេធាវីការពារក្តី" សម្រាប់សារណាតបរបស់ខ្លួន[8]។

៦. នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ លោក នួន ជា បានទទួលមរណភាព។

៧. តាមរយៈសារណានេះ មេធាវីការពារក្តីសូមជំទាស់ទៅនឹងសំណើបន្ទាប់បន្សំថ្មីរបស់សហព្រះរាជអាជ្ញា ដែលមានភាពប្រែប្រួលមិនឈប់ឈរ និងគ្មានមូលដ្ឋានគាំទ្រ (ផ្នែកទី I) មិនសមហេតុផល (ផ្នែកទី II) និងយឺតពេល (ផ្នែកទី III)។

## I. សំណើដែលមានភាពប្រែប្រួលមិនឈប់ឈរ និងគ្មានមូលដ្ឋានគាំទ្រ

[6] ការឆ្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងចម្លើយតបទាក់ទងនឹងសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **F45/3** ជូនដំណឹងនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩។

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំពេលវេលា និងចំនួនទំព័របន្ថែម សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F47/1** ("ចម្លើយតប/សំណើ **F47/1**")។ មេធាវីការពារក្តីបានធ្វើការដោយផ្អែកលើសំណៅបកប្រែព្រាងដំបូងមិនពេញលេញជាភាសាបារាំង ដែលផ្តល់ជូនដោយអង្គភាពបកប្រែភាសា ដោយសារតែមិនអាចបកប្រែឯកសារទាន់ពេលវេលា។

[8] ចម្លើយតប/សំណើ **F47/1** កថាខណ្ឌ ២៥-២៦(ii)។

៨. នៅក្នុងបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញាបានស្នើសុំជាលក្ខណៈប្រព័ន្ធឱ្យបន្ថែមចំនួនទំព័រ និង/ឬពេលវេលាដូចគ្នាទៅនឹងការផ្តល់ជូនមេធាវីការពារក្តីទាំងពីរក្រុម សម្រាប់ការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ ឬការសួរដេញដោលសាក្សី[9]។ តុលាការកំពូលបានបដិសេធសំណើនេះជាលក្ខណៈប្រព័ន្ធ ដោយពិចារណាឃើញថាពុំមានមូលហេតុត្រឹមត្រូវ[10]។ នៅចំពោះមុខ "ភាពរឹងទទឹង"[11] របស់សហព្រះរាជអាជ្ញា តុលាការកំពូលថែមទាំងបានរម្លឹកទៀតថា មានភាពខុសគ្នាជាមូលដ្ឋានរវាងតួនាទីរបស់ជនជាប់ចោទ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងតួនាទីរបស់អាជ្ញាធរចោទប្រកាន់[12]។

---

[9] ក្នុងករណីនៃសារណាបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាសម្រាប់ឆ្លើយតប ដូចគ្នានឹងពេលវេលាដែលបានផ្តល់ជូនមេធាវីការពារក្តីទាំងពីរក្រុម និងបានស្នើសុំចំនួនទំព័រស្មើនឹងសារណាបណ្តឹងសាទុក្ខទាំងពីរបូកបញ្ចូលគ្នា (យោងនៅក្នុងកំណត់សម្គាល់ជើងទំព័របន្ទាប់)។

[10] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ឯកសារ **F3/3** កថាខណ្ឌ ៥ និងកថាខណ្ឌ ១០, សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ **F9** ("សេចក្តីសម្រេច **F9**") កថាខណ្ឌ ៨-៩ កថាខណ្ឌ ១៥ កថាខណ្ឌ ១៧ កថាខណ្ឌ ២០-២១ កថាខណ្ឌ ២៣,សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ និងពេលវេលា ក្នុងការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **F23/1** ("សេចក្តីសម្រេច **F23/1**") កថាខណ្ឌ ៩ និងកថាខណ្ឌ ១១, សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **F26/2/2** ("សេចក្តីសម្រេច **F26/2/2**") កថាខណ្ឌ ៦-៨។

[11] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រសម្រាប់ដាក់សារណាតបទៅនឹងសំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភ័ស្តុតាងបន្ថែម ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ឯកសារ **F2/8/2/1** ទំព័រ ៥៖ "ទោះបីជាមានការបញ្ជាក់ច្បាស់លាស់នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលលើបញ្ហានេះក៏ដោយ ក៏សហព្រះរាជអាជ្ញានៅតែទទូចធ្វើយុត្តិកម្មទៅលើដំណោះស្រាយដែលបានស្នើឡើង ដោយធ្វើការយោងទៅលើសំណើរបស់ភាគីដទៃទៀត"។

[12] សេចក្តីសម្រេច **F26/2/2** កថាខណ្ឌ ៦៖ "អង្គជំនុំជម្រះតុលាការកំពូលរម្លឹកថា មានភាពខុសគ្នាជាមូលដ្ឋានរវាងតួនាទីរបស់ជនជាប់នៅក្នុងការជំនុំជម្រះព្រហ្មទណ្ឌ ដែលជនជាប់ចោទពុំមានសេរីភាព ដូចនេះត្រូវទទួលបានសិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានចែងជាពិសេស ក្នុងមាត្រា ១៤(២) និង (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងតួនាទីរបស់អយ្យការដែលតំណាងឱ្យផលប្រយោជន៍សាធារណៈ ដែលត្រូវតែផ្តល់យុត្តិធម៌ ដោយអនុលោមតាមច្បាប់"។

៩. ជាពិសេស ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីទាំងពីរក្រុម តុលាការកំពូលបានផ្តល់ចំនួនទំព័រដូចគ្នា ដោយបន្ថែមមួយភាគបី (គឺមិនមែនស្មើនឹងចំនួនទំព័រនៃសារណាទាំងពីបូកបញ្ចូលគ្នា តាមការស្នើសុំនោះទេ)[13] និងតិចជាងមួយភាគបីនៃពេលវេលា ដែលបានផ្តល់ជូនមេធាវីការពារក្តីទាំងពីរក្រុម (គឺមិនមែនពេលវេលាដូចគ្នា តាមការស្នើសុំនោះទេ)[14]។ ជាក់ស្តែង ពេលមេធាវីការពារក្តីបានទទួល ៩០ ថ្ងៃ និង ២១០ ទំព័រ សម្រាប់ដាក់សារណា តែមួយភាសា សហព្រះរាជអាជ្ញាបានទទួល ៣០ ថ្ងៃ និង ២៨០ ទំព័រ សម្រាប់ចម្លើយតបជាពីរភាសា[15]។

១០. ក្នុងសំណុំរឿង ០០២/០២ ជាការឆ្លើយតបទៅនឹងមេធាវីការពារក្តី សហព្រះរាជអាជ្ញាបានស្នើសុំថាសម្រាប់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ ការបន្ថែមត្រូវ "សមាមាត្រ" នឹងការផ្តល់ជូនមេធាវីការពារក្តីទាំងពីរក្រុម[16]។ មេធាវីការពារក្តីយល់ថា សហព្រះរាជអាជ្ញាបានបោះបង់សំណើមិនសមហេតុផលរបស់ខ្លួន ក្នុងសំណុំរឿង ០០២/០១ ហើយជាចុងក្រោយ យកតាមការសម្រេចរបស់តុលាការកំពូល និងយុត្តិសាស្រ្តក្នុងសំណុំរឿង ០០២/០១។

១១. ទោះជាយ៉ាងនេះក្តី ១០ ថ្ងៃក្រោយមក ជាការឆ្លើយតបទៅនឹងមេធាវីការពារក្តីលោក នួន ជា សហព្រះរាជអាជ្ញាបានប្រកាន់ជំហរថ្មី។ ឥឡូវនេះ សហព្រះរាជអាជ្ញាបែរជាស្នើសុំ "យ៉ាងហោចណាស់

---

[13] សេចក្តីសម្រេច **F9** កថាខណ្ឌ ១៥ និងកថាខណ្ឌ ១៧។ តុលាការកំពូលបានផ្អែកលើវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ក្នុងករណីនៃការជំនុំជម្រះក្តីលើជនជាប់ចោទច្រើនរូប។ យោងតាមវិធានទាំងនេះ ក្នុងករណីមានម្ចាស់បណ្តឹងសាទុក្ខតែម្នាក់ ភាគីចុងចម្លើយទទួលបានចំនួនទំព័រដូចគ្នានឹងម្ចាស់បណ្តឹងសាទុក្ខ ដើម្បីឆ្លើយតប (កថាខណ្ឌ ១៥ កំណត់សម្គាល់ជើងទំព័រលេខ ៣០-៣១)។

[14] សេចក្តីសម្រេច **F9** កថាខណ្ឌ ២០ និងកថាខណ្ឌ ២១ ("អង្គជំនុំជម្រះតុលាការកត់សម្គាល់ថា ជាទូទៅ តុលាការមិនអចិន្ត្រៃយ៍ តែងផ្តល់ពេលវេលាឲ្យប្រហែលពាក់កណ្តាល ចំពោះសារណាតប ធៀបទៅនឹងពេលវេលាដែលផ្តល់ឲ្យសម្រាប់សារណាបណ្តឹងសាទុក្ខ ហើយអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សហព្រះរាជអាជ្ញានឹងអាចធ្វើការពិភាក្សា ព្រមទាំងដំណើរការការងារបឋមបានយ៉ាងច្រើន នៅក្នុងការរៀបចំសារណាតបរបស់ខ្លួន នៅពេលបានទទួលសារណាបណ្តឹងសាទុក្ខ ជាភាសាអង់គ្លេស ឬភាសាបារាំង" កថាខណ្ឌ ២០)។

[15] សេចក្តីសម្រេច **F9** កថាខណ្ឌ ២៣។

[16] ចម្លើយតប **F45/2** កថាខណ្ឌ ១៨ និងកថាខណ្ឌ ២២។

៧0% នៃចំនួនទំព័រសរុបរួម និង ៥0% នៃពេលវេលារួម ដែលផ្តល់ជូនមេធាវីការពារក្តី"។ សហព្រះរាជអាជ្ញាក៏ស្នើសុំផងដែរថា រយៈពេលដាក់ចម្លើយតប "តែមួយភាសា" គួរត្រូវបាន "យ៉ាងហោចណាស់ ៤៥ ថ្ងៃ បន្ទាប់ពីមេធាវីការពារក្តីដាក់សារណាបណ្តឹងសាទុក្ខ ជាភាសាខ្មែរ"[17]។

១២. សហព្រះរាជអាជ្ញាមិនត្រឹមតែមិនពន្យល់អំពីការផ្លាស់ប្តូរជំហរទាន់ហន់បែបនេះនោះទេ ថែមទាំងមិនផ្តល់ហេតុផលចំពោះការស្នើសុំរបស់ខ្លួនទៀតផង។ សហព្រះរាជអាជ្ញាគ្រាន់តែយោងទៅរកមូលហេតុដែលបញ្ជាក់ថា មេធាវីការពារក្តីទាំងពីរក្រុមគួរទទួលបានត្រឹមតែ ៥ ខែ តែមួយភាសា និង ៣00 ទំព័រ ហើយក្នុងលក្ខណៈចម្រូងចម្រាសគ្នា សហព្រះរាជអាជ្ញានិយាយសំដៅដល់ "បញ្ហាមួយចំនួន" ដែល នួន ជា និង ខៀវ សំផន ចង់ប្តឹង[18]។ ថ្វីត្បិតតែមិនបានស្នើសុំ ដូចក្នុងសំណុំរឿង 00២/0១ នូវចំនួនទំព័រស្មើនឹងសារណាបណ្តឹងសាទុក្ខទាំងពីរបូកបញ្ចូលគ្នា សហព្រះរាជអាជ្ញាមិនបានពន្យល់ថា ហេតុអ្វីបានជាខ្លួនគួរទទួលបានយ៉ាងហោចណាស់ ៧0% នៃចំនួនទំព័រសរុបរួម គឺលើសចំនួនទំព័រដូចគ្នាដោយបន្ថែមមួយភាគបី ដូចបានផ្តល់ជូនក្នុងសំណុំរឿង 00២/0១ ទៅទៀត។ ទន្ទឹមនឹងនេះ សហព្រះរាជអាជ្ញាមិនពន្យល់ថា ហេតុអ្វីបានជាស្នើសុំ ដូចក្នុងសំណុំរឿង 00២/0១ នូវពេលវេលាដូចគ្នានឹងការផ្តល់ជូនមេធាវីការពារក្តីទាំងពីរក្រុម[19] គឺលើសមួយភាគបី ដូចបានផ្តល់ជូនក្នុងសំណុំរឿង 00២/0១ ទៅទៀត។ សហព្រះរាជអាជ្ញាមិនពន្យល់ថា ហេតុអ្វីបានជាខ្លួនគួរទទួលបានការអនុញ្ញាតឲ្យដាក់ចម្លើយតប តែមួយភាសា។ម្យ៉ាងទៀត សហព្រះរាជអាជ្ញាមិនផ្តល់សំអាងហេតុយកជាការបានដែលបញ្ជាក់ថា តុលាការកំពូលងាកចេញពីយុត្តិសាស្ត្ររបស់ខ្លួន ក្នុងសំណុំរឿង 00២/0១ នោះទេ។

១៣. តាមពិត សហព្រះរាជអាជ្ញាមិនអាចធ្វើបានទេ។ សំណើមិនសមហេតុផលរបស់សហព្រះរាជអាជ្ញាហាក់ដូចជាគ្រាន់តែមានគោលដៅបំភ័យតុលាការកំពូលដោយខុសឆ្គង ពាក់ព័ន្ធនឹងរយៈពេលដែលមេធាវីការពារក្តីបានស្នើសុំ។

---

[17] ចម្លើយតប/សំណើ **F47/1** កថាខណ្ឌ ២៥-២៦(ii)។

[18] ចម្លើយតប/សំណើ **F47/1** កថាខណ្ឌ ២៥។

[19] "៥0% នៃពេលវេលារួម" ដែលផ្តល់ជូនមេធាវីការពារក្តីទាំងពីរក្រុម ស្មើនឹងពេលវេលាដូចគ្នា ដែលផ្តល់ជូនក្រុមមេធាវីការពារក្តីនីមួយៗ។

## II. សំណើមិនសមហេតុផល និងមានគោលដៅបំពានយុត្តិធម៌តុលាការកំពូល

១៤. ក្នុងសំណុំរឿង ០០២/០២ វាគ្មានហេតុផលណាមួយដែលត្រូវធ្វើការបន្ថែមលើសមាមាត្រពេលវេលាដែលបានផ្តល់ឲ្យនៅក្នុងសំណុំរឿង ០០២/០១ ដើម្បីឲ្យសហព្រះរាជអាជ្ញាឆ្លើយតបនោះទេ។ ករណីបែបនេះធ្លាប់មានរួចមកហើយ នៅពេលសហព្រះរាជអាជ្ញាត្រូវឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខចំនួនពីរ ហើយនៅពេលនេះ ការមិនបន្ថែមពេលវេលាកាន់តែត្រឹមត្រូវថែមទៀតព្រោះថាលោក នួន ជា បានស្លាប់ទៅហើយ។

១៥. នៅពេលធ្វើសំណើសុំ សហព្រះរាជអាជ្ញាបានដឹងថា ដូចគ្នានឹងសំណុំរឿង ០០២/០១ ដែរ សំណុំរឿង ០០២/០២ គឺជារឿងក្តីដែលមានជនជាប់ចោទពីររូប ហើយលើសពីនេះ ពួកគាត់ត្រូវបានផ្តន្ទាទោសដោយសារបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមតែមួយ។ សហព្រះរាជអាជ្ញាបានដឹងដែរថា ដូចក្នុងសំណុំរឿង ០០២/០១ ដែរ ខ្លួនអាចចាប់ផ្តើមរៀបចំចម្លើយតប ចាប់ពីពេលមានសេចក្តីជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខ តែមួយភាសា ហើយដាក់ចម្លើយតបនោះជាពីរភាសានៅពេលក្រោយមកទៀត បន្ទាប់ពីមានសេចក្តីជូនដំណឹងអំពីសារណាទាំងនោះជាភាសាខ្មែរ។

១៦. ពេលសហព្រះរាជអាជ្ញាត្រូវឆ្លើយតបទៅម្ចាស់បណ្តឹងសាទុក្ខពីររូប ខ្លួនបានដឹងថាបញ្ហាទាំងឡាយដែលអ្នកទាំងពីរនឹងលើកឡើងក្នុងបណ្តឹងសាទុក្ខរបស់ពួកគាត់ គឺជាទូទៅត្រួតគ្នា។ ជាក់ស្តែងដូចដែលបានបង្ហាញឲ្យឃើញតាមរយៈការណ៍ដែលសំអាងហេតុនៃសាលក្រម លើកឡើងពីជនជាប់ចោទម្នាក់ៗ ក្នុងចំនួនទំព័រតិចបំផុតលើចំនួនទំព័រសរុប៖

| | ចំនួនទំព័រសរុប រួមទាំងឧបសម្ព័ន្ធ | ចំនួនទំព័រនិយាយអំពីតួនាទី និងការទទួលខុសត្រូវរបស់ នួន ជា | ចំនួនទំព័រនិយាយអំពីតួនាទី និងការទទួលខុសត្រូវរបស់ ខៀវ សំផន |
|---|---|---|---|
| ភាសាបារាំង | ២ ៨២៨ | ៩១ (៣,២១%) | ១៣៧ (៤,៨៤%) |
| ភាសាអង់គ្លេស | ២ ៣៨៧ | ៧៨ (៣,២៦%) | ៩២ (៣,៨៥%) |

១៧. បញ្ហាភាគច្រើនដែលត្រូវបានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខរបស់សហជនជាប់ចោទទាំងពីរ គឺដូចគ្នា (ការដឹកនាំដំណើរការនីតិវិធី ច្បាប់ជាធរមានចំពោះឧក្រិដ្ឋកម្ម ទម្រង់នៃការទទួលខុសត្រូវ ការវាយតម្លៃលើភស្ដុតាង)។ លើសពីនេះទៀត ជនជាប់ចោទទាំងពីររូបត្រូវបានផ្ដន្ទាទោសជារួម ដោយសារការចូលរួមរបស់ពួកគាត់ក្នុងសហឧក្រិដ្ឋកម្មរួមដូចគ្នា ដែលក្នុងនោះ ផែនការរួមទំនងជាត្រូវបានដាក់ឲ្យអនុវត្តតាមរយៈ "គោលនយោបាយ" ចំនួនប្រាំ (ដែលគោលនយោបាយនីមួយៗហាក់ដូចជាបានបង្កឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មយ៉ាងច្រើន) ដែលជនជាប់ចោទទាំងពីរបានយល់ស្រប និងចូលរួម។

១៨. ហេតុដូច្នេះ ដើម្បីឆ្លើយតបទៅបណ្ដឹងសាទុក្ខដែលនឹងមានលក្ខណៈច្រំដែលច្រើននោះ សហព្រះរាជអាជ្ញាមិនត្រូវការពេលវេលាច្រើនលើសពីអ្វីដែលខ្លួនទទួលបាននៅក្នុងសំណុំរឿង ០០២/០១ នោះទេ។ ជាថ្មីម្ដងទៀត ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាអាចទាញយកផលចំណេញបានយ៉ាងច្រើនពីពេលវេលានៃការបកប្រែសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីជាភាសាខ្មែរ។ នេះជាអ្វីដែលសហព្រះរាជអាជ្ញាមានចេតនាធ្វើមិនដឹង ហើយទន្ទឹមគ្នានោះដែរ សហព្រះរាជអាជ្ញាបានលើកឡើងជាលក្ខណៈទាក់ទាញចំណាប់អារម្មណ៍ថា ការអនុញ្ញាតតាមសំណើសុំរបស់មេធាវីការពារក្ដីមានន័យថាពេលវេលាសម្រាប់សារណាបណ្ដឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្ដីតែមួយមុខ អាចនឹងត្រូវប្រើពេលជិតពីរឆ្នាំ[20]។

១៩. នៅពេលលើកសំណើ សហព្រះរាជអាជ្ញាបានដឹងថា ទោះជាមានអំណះអំណាងត្រឹមត្រូវថាពេលវេលាត្រូវការសម្រាប់សារណាបណ្ដឹងសាទុក្ខ ត្រូវតែមានចំនួនច្រើនជាងពេលវេលានៅក្នុងសំណុំរឿង ០០២/០១ ក៏ដោយ ក៏ពេលវេលាបកប្រែសារណាទាំងនោះជាភាសាខ្មែរ នឹងមិនបាត់បង់នោះទេ។ ដូចគ្នាទៅនឹងសំណុំរឿង ០០២/០១ ដែរ ពេលវេលានឹងត្រូវចំណាយ ១) មួយផ្នែកសម្រាប់ការរៀបចំចម្លើយតបរបស់ក្រុមមេធាវីការពារក្ដីទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជ

[20] ចម្លើយតប/សំណើ **F47/1** កថាខណ្ឌ ២៣៖ "ការណ៍នេះនឹងមានន័យថា ពេលវេលាសម្រាប់បណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី *តែឯង* ក្នុងសំណុំរឿង ០០២/០២ នឹងប្រើពេលជិតពីរឆ្នាំ។" (សរសេរជាអក្សរទ្រេតក្នុងអត្ថបទដើម)។

អាជ្ញា[21] ហើយ ២) នឹងត្រូវចំណាយទាំងស្រុងសម្រាប់រៀបចំចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តី។

២០. នៅក្នុងសំណុំរឿង ០០២/០១ តុលាការកំពូលបានគូសបញ្ជាក់ពីការណ៍ដែលសហព្រះរាជអាជ្ញាអាចធ្វើការលើចម្លើយតបរបស់ខ្លួន បន្ទាប់ពីទទួលបានសារណាបណ្តឹងសាទុក្ខ តែមួយភាសា[22]។ មេធាវីការពារក្តីលើកឡើងបន្ថែមថា បច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាអាចប្រើប្រាស់ធនធានរបស់ខ្លួនស្ទើរតែទាំងស្រុងសម្រាប់សំណុំរឿង ០០២/០២[23] ហើយថាសហព្រះរាជអាជ្ញាមានអ្នកប្រែខាងក្នុងរបស់ខ្លួន (ខុសគ្នាពីមេធាវីការពារក្តី)[24]។

២១. ដូច្នេះ តុលាការកំពូលគួរតែបង្គាប់ឲ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតប ជាពីរភាសា មិនឲ្យលើសពីរយៈពេល ១៥ ថ្ងៃ ក្រោយពីមានសេចក្តីជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីជាភាសាខ្មែរ។

---

[21] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **F13/2** កថាខណ្ឌ ១២-១៣ និង ១៧ (តុលាការកំពូលបានលើកពេលចាប់ផ្តើមនៃរយៈពេលឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី ដោយគិតចាប់ពីពេលដែលមេធាវីការពាក្តីដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ក្នុងមួយភាសា)។

[22] សេចក្តីសម្រេច **F9** កថាខណ្ឌ ២០ (សូមមើលខាងលើ កំណត់សម្គាល់ជើងទំព័រ ១៤), សេចក្តីសម្រេច **F23/1** កថាខណ្ឌ ១១ "ទាក់ទងនឹងការជំទាស់ដែលថា ថិរវេលា ៣០ ថ្ងៃ ពុំអាចគ្រប់គ្រាន់សម្រាប់បុគ្គលិកជាតិ និងអន្តរជាតិនៃការិយាល័យសហព្រះរាជអាជ្ញាធ្វើការជាមួយនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសហការនេះគប្បីធ្វើឡើងចាប់តាំងពីពេលដាក់សារណាលើបណ្តឹងសាទុក្ខតែមួយភាសាជាអង់គ្លេសមកម្លេះ។ ជាការពិតដែលថា សហព្រះរាជអាជ្ញាជាប្រចាំតែងតែស្នើសុំដាក់ឯកសារតែមួយភាសា ដែលឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយនោះ គឺជាការបង្ហាញនូវការសហការដែលកើតមានតាំងពីដំបូងមកហើយ"។

[23] សំណុំរឿង ០០៤/១ បានបិទបញ្ចប់។ សំណុំរឿង ០០៤/២ កំពុងស្ថិតក្នុងការពិភាក្សាសម្រេចរបស់អង្គបុរេជំនុំជម្រះ។ សំណុំរឿង ០០៣ ស្ថិតក្នុងដំណាក់កាលនៃការឆ្លើយតបទៅនឹងចម្លើយតប ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍។ នៅសល់តែសំណុំរឿង ០០៤ ប៉ុណ្ណោះ ដែលក្នុងនោះ ដំណាក់កាលនៃការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ បានចាប់ផ្តើមកាលពីខែមុន។

[24] ឧទាហរណ៍ សូមមើល សារអេឡិកត្រូនិករបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង ១៣.០៦ នាទី មានចំណងជើងថា "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំឲ្យកោះហៅ ប្រាក់ ខន ឡើងវិញ - សំណើសុំដាក់ឯកសារតែមួយភាសា" ឯកសារ **E409/2.1.2** ទំព័រ ២ កថាខណ្ឌ ២ [សារជាភាសាអង់គ្លេស]។

២២. ក្នុងស្ថានភាពបែបនេះ សហព្រះរាជអាជ្ញានឹងមានលទ្ធភាពយ៉ាងស្រួលក្នុងការដាក់ចម្លើយតបមួយយ៉ាងពេញលេញ ទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ដោយពុំធ្វើឱ្យយឺតយ៉ាវដល់ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ។

### III. **<u>សំណើហួសពេល</u>**

២៣. ទោះបីជាសំណើនេះពន្យារពេលវេលាក្នុងការចេញសេចក្ដីសម្រេចក៏ដោយ ក៏ពេលខ្លះ ការអនុវត្តនៃការដាក់សំណើបន្ទាន់បង្ខំធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណើសុំផ្សេងៗ អាចមានមូលហេតុត្រឹមត្រូវ។ ប៉ុន្តែ មេធាវីការពារក្ដីឆ្ងល់ថាហេតុអ្វីបានជាសហព្រះរាជអាជ្ញាមិនធ្វើសំណើនេះ ១០ ថ្ងៃ មុននេះ នៅពេលដែលឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្ដី។ បើបានធ្វើដូចនេះ មេធាវីការពារក្ដីនឹងមិនចាំបាច់ចំណាយធនធានធ្វើការលើបញ្ហានេះឡើងវិញ ហើយថែមទាំងបន្ទាន់ទៀតផង ដើម្បីឆ្លើយតបឱ្យបានឆាប់បំផុត កុំឱ្យយឺតយ៉ាវដល់ការចេញសេចក្ដីសម្រេចរបស់តុលាការកំពូល។ មូលហេតុគឺថា សេចក្ដីសម្រេចនេះត្រូវតែចេញឱ្យបានឆាប់បំផុត ព្រោះវាជាកត្តាកំណត់ពីដំណាក់កាលបន្តមកទៀតនៃដំណើរការនីតិវិធីបច្ចុប្បន្ន ហើយវាអាចឱ្យភាគីទាំងអស់មានលទ្ធភាពរៀបចំខ្លួនបានល្អ។

២៤. **<u>យោងតាមសំអាងហេតុនេះ</u>** មេធាវីការពារក្ដីស្នើតុលាការកំពូលមេត្តា៖

- **បដិសេធ**សំណើរបស់សហព្រះរាជអាជ្ញា និងផ្ដល់ឱ្យសហព្រះរាជអាជ្ញានូវពេលវេលាបន្ថែមសមាមាត្រ ស្របតាមយុត្តិសាស្ត្ររបស់តុលាការកំពូលនៅក្នុងសំណុំរឿង ០០២/០១។
  **សម្រេច**ជាបន្ទាន់លើសំណើសុំទាំងអស់ ដោយចេញផ្នែកសម្រេចសេចក្ដីមុន រួចសឹមចេញសំអាងហេតុពេលក្រោយ។

| | | |
|---|---|---|
| មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |